# RHAC អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់)

## សិទ្ធិរបស់អតិថិជន មានដូចខាងក្រោម :

### ១~ សិទ្ធិក្នុងការទទួលយកព័ត៌មាន



អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលយកព័តិមានស្ដីអំពីផលប្រយោជន៍នៃការពន្យារកំណើត ទីកន្លែងផ្ដល់សេវាពន្យារកំណើត និងសេវាថែទាំសុខភាពផ្លូវភេទ ។

### ២~ សិទ្ធិក្នុងការទទួលសេវា



អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាពន្យារកំណើតដោយមិនគិតអំពីស្ថានភាពសង្គម សេដ្ឋកិច្ច សាសនា និន្នាការនយោបាយ ជនជាតិ ពណ៌សម្បុរ ស្ថានភាពអាពាហ៏ពិពាហ៏ ឬ ទីកន្លែងស្នាក់នៅឡើយ ។

### ៣~ សិទ្ធិក្នុងការជ្រើសរើស



អតិថិជនទាំងអស់មានសិទ្ធិសម្រេចចិត្តក្នុងការជ្រើសរើស ប្រើប្រាស់ ឬ មិនប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយដោយសេរី ។

### ៤~ សិទ្ធិមានសុវត្ថិភាព



អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលបាននូវសុវត្ថិភាព សុខភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្តក្នុងការប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយ ។

### ៥~ សិទ្ធិឯកជន



អតិថិជនទាំងអស់មានសិទ្ធិក្នុងការពិភាក្សាតម្រូវការ ការព្រួយបារម្ភ ឬការពិនិត្យរាងកាយរបស់ពួកគេ នៅក្នុងទីកន្លែងណាដែលគេមានអារម្មណ៏កក់ក្ដៅ ។

### ៦~ សិទ្ធិរក្សាការម្ងាត់



អតិថិជនទាំងអស់ គួរតែត្រូវបានធានាថារាល់ព័តិមានទាំងឡាយដែលគេបានប្រាប់ ឬសេវាទាំងឡាយដែលគេបានទទួលនឹងមិនត្រូវបន្តទៅអ្នកទី៣ទេ លើកលែងតែមានការយល់ព្រមពីសាមុីខ្លួន ។

### ៧~ សិទ្ធិរក្សាភាពថ្លៃថ្នូរ និងកិត្តិយស



អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលរាក់ទាក់ដោយភាពគួរសម ការយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន និងការគោរពដោយភាពថ្លៃថ្នូរ ដោយមិនប្រកាន់នូវចំណេះដឹង ស្ថានភាពសង្គម ឬឋានន្តរសក្តិឡើយ ។

### ៨~ សិទ្ធិមានផាសុកភាព



អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាកម្មដែលមានលក្ខណៈផាសុកភាពដោយអារម្មណ៏ពេញចិត្តពេញថ្លើម ។

### ៩~ សិទ្ធិក្នុងការបន្ត



អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាកម្ម និងមធ្យោបាយពន្យារកំណើតបានយូរទៅតាមសេចក្ដីត្រូវការរបស់ពួកគេ ។

### ១០~ សិទ្ធិក្នុងការបញ្ចេញមតិយោបល់



អតិថិជនទាំងអស់មានសិទ្ធិក្នុងការបញ្ចេញយោបល់ និងទស្សនៈអំពីការផ្ដល់សេវាកម្មដែលពួកគេបានទទួល ។

RHAC IPPF WHO